សមាគមស៊ីកាដា
cicada ASSOCIATION

ពិព័ណ៌នាការងារជាមួយសមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកៃច្នៃនៃកម្ពុជា (សមាគមស៊ីកាដា)

## ក) ព័ត៌មានទូទៅ៖

| | |
|---|---|
| តួនាទី | អ្នកហាត់ការការងារ |
| ទីកន្លែង | ភ្នំពេញ |
| រាយការណ៍ជូន | នាយិកា និងអ្នកសម្របសម្រួលសមាគស៊ីកាដា |
| ប្រភេទនៃកិច្ចសន្យា | មានដែនកំណត់ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០២៤ |

## ខ) សារតារ៖

សមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកៃច្នៃនៃកម្ពុជា (សមាគមស៊ីកាដា) ជាសមាគមទើបបានបង្កើតថ្មីដោយចង់មើលឃើញវិស័យវប្បធម៌ និងច្នៃប្រតិដ្ឋរីកចម្រើន, ចម្រុះ, និងមានសិទ្ធិអំណាច ដែលចូលរួមដល់ភាពរីកចម្រើននៃសង្គមកម្ពុជា។ បេសសកកម្មរបស់ពួកយើង គឺធ្វើឱ្យមានផលប៉ះពាល់ដល់គោលនយោបាយតាមរយៈការស្រាវជ្រាវ, ការកសាងសមត្ថភាព, និងការសន្ទនា ដែលរួមគ្នាអភិវឌ្ឍ និងធ្វើឱ្យរីកចម្រើននៃវិស័យ វប្បធម៌ និងច្នៃប្រតិដ្ឋ សម្រាប់ការទទួលស្គាល់ថ្នាក់ជាតិ និងសកលលោកចំពោះសិល្បៈ វប្បធម៌ និងច្នៃប្រតិដ្ឋនៃកម្ពុជា។ សមាគមស៊ីកាដា មានផែនការអទិភាពជាយុទ្ធសាស្ត្រចំនួន ៥ រួមមាន៖ ការតស៊ូមតិ និងគោលនយោបាយ ការស្រាវជ្រាវ សមាជិកភាព ការកសាងបណ្តាញដៃគូ និងការអភិវឌ្ឍស្ថាប័ន ។ ស៊ីកាដា មានគោលបំណងធ្វើជាតំណាង និងស្វែងរកការគាំទ្រនូវឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព និងបរិយាបន្នមួយដែលធានាថាឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌គឺជាបេះដូងនៃការសម្រេចចិត្តក្នុងគោលនយោបាយ សេដ្ឋកិច្ច និងសង្គម។ គេហទំព័រ https://www.cicadakh.org/en/

## គ) សារតារនៃការងារហាត់ការ៖

នៅក្នុងផែនការយុទ្ធសាស្ត្រមួយក្នុងចំណោមទាំងប្រាំ គឺ សមាជិកភាព ដែលសមាគមស៊ីកាដាត្រូវធ្វើការជិតស្និទ្ធជាមួយសមាជិក ដើម្បីអាចឆ្លើយតបនឹងតម្រូវការរបស់សមាជិក ក៏ដូចជាបង្កើនអត្ថប្រយោជន៍ដល់សមាជិក។ ជាពិសេសក្នុងឆ្នាំ ២០២៤នេះ សមាគមស៊ីកាដាមានបំណងបង្ហាញពីសមាសភាពនៃសមាជិករបស់ខ្លួន ក្នុងគោលបំណងណែនាំជូនសហគមន៍វប្បធម៌ និងច្នៃប្រតិដ្ឋ និងជួយផ្សព្វផ្សាយពីសិល្បករ និងស្ថាប័នរបស់សមាជិកនីមួយៗឲ្យកាន់តែទូលំទូលាយ។ បន្ថែមជាងនេះទៀត សមាគមស៊ីកាដាមានបំណងផ្តល់ព័ត៌មានអំពីការវិវត្តនៃកិច្ចគាំពារសង្គម ជូនដល់សមាជិក និងសិល្បករ និងប្រតិបត្តិករវប្បធម៌ ដែលបានឆ្លើយតបសម្ភាសគម្រោងស្រាវជ្រាវរបស់សមាគមកន្លងមក។

ដូចនេះ សមាគមស៊ីកាដាកំពុងស្វែងរកអ្នកហាត់ការចំនួនមួយនាក់ (០១) ដើម្បីគាំទ្រការងារសមាគមទាក់ទងនឹងសមាជិកភាព។ សូមអានព័ត៌មានសំខាន់ៗទាក់ទងនឹងការទទួលខុសត្រូវ និងបទពិសោធន៍ចាំបាច់នានាដូចខាងក្រោម។

## ឃ) តួនាទី និងការទទួលខុសត្រូវ៖

- ឈ្វេងយល់អំពីការងារស៊ីកាដា តាមរយៈការណែនាំអំពីការងារ
- រៀបផែនការការងារ តាមការណែនាំរបស់អ្នកសម្របសម្រួលសមាគមស៊ីកាដា
- ប្រមូលព័ត៌មានសារតារ ឬអត្ថបទសង្ខេបចាំបាច់ពីសមាជិក និងចងក្រង រក្សាទុកក្នុងប្រព័ន្ធទិន្នន័យរបស់ស៊ីកាដា
- ផ្តល់ជូននូវព័ត៌មានស្តីអំពី បេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដល់សមាជិក នៅតាមបណ្តារាជធានី និងខេត្ត
- ផ្តល់ការគាំទ្រដល់ការងារទាក់ទងនឹងការផ្សព្វផ្សាយ
- ប្រជុំដើម្បីធ្វើបច្ចុប្បន្នភាពការងារ

## ង) ជំនាញ និងបទពិសោធន៍៖

- មានបទពិសោធន៍ក្នុងការដកស្រង់ និងរក្សាទុកព័ត៌មាន
- មានជំនាញសម្របសម្រួលការងារ
- មានការគ្រប់គ្រងពេលវេលា
- និយាយ និងសរសេរភាសាខ្មែរបានល្អ និងភាសាអង់គ្លេសខ្លះរឹតតែប្រសើរ
- ចេះប្រើកម្មវិធី Microsoft Office និង កម្មវិធីកាត់តរូបភាព Illustrator (រឹតតែប្រសើរ តែមិនចាំបាច់)
- មានទំនាក់ទំនងល្អ
- ចង់រៀនសូត្រអ្វីដែលថ្មីៗ
- មានភាពបត់បែនចំពោះការងារ
- មានចំណាប់អារម្មណ៍ក្នុងវិស័យសិល្បៈ និងវប្បធម៌នៅកម្ពុជា
- មានពេលយ៉ាងតិច ៣ ពេល ក្នុងមួយសប្តាហ៍ (អាចចរចាបាន)

## ច) អត្ថប្រយោជន៍៖

- ទទួលបានបទពិសោធន៍ការងារទាក់ទងនឹងសមាជិកភាព ការប្រមូល និងរក្សាទុកព័ត៌មាន
- ទទួលបានចំណេះដឹងទាក់ទងនឹងវប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋ
- បង្កើនបណ្តាញទំនាក់ទំនងក្នុងសហគមន៍សិល្បៈ វប្បធម៌ និងច្នៃប្រតិដ្ឋ
- ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ
- លិខិតបញ្ជាក់អំពីការងារហាត់ការ

## ឆ) របៀបផ្ញើចំណាប់អារម្មណ៍៖

ដើម្បីផ្ញើចំណាប់អារម្មណ៍ សូមផ្ញើ ដោយប្រាប់ថា ហេតុអ្វីបានជាអ្នកចាប់អារម្មណ៍នឹងការងារហាត់ការនេះ និងប្រវត្តិរូបសង្ខេប ដែលមានអ្នកជាអំណះអំណាងចំនួន ០២ រូប មក Info@cicadakh.org។

ថ្ងៃផុតកំណត់ឈប់ទទួលពាក្យ៖ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០២៣។ បេក្ខជនបីនាក់នឹងត្រូវជ្រើសរើស ដើម្បីសម្ភាសផ្ទាល់មាត់ក្នុងអំឡុងសប្តាហ៍ទីមួយ នៃខែមករា។ កាលបរិច្ឆេទចាប់ផ្តើមការងារ៖ អាចបត់បែនបាន តែយ៉ាងយូរចាប់ត្រឹម ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៤។ ស្ត្រី និងជនមានពិការភាព ត្រូវបានលើកទឹកចិត្ត។

***សម្រាប់សំណួរផ្សេងៗ សូមទាក់ទងមក សាគុណា តាមរយៈលេខ ០១២ ៨៣២ ២០១*